**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៩..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតក្រុមការងារពិសេស
## ដើម្បីគាំទ្រការអនុវត្តផ្ទាល់ដល់គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## សម្រេច

**មាត្រា១.-**

បង្កើតក្រុមការងារពិសេសមួយ ដើម្បីគាំទ្រដល់ការអនុវត្តផ្ទាល់របស់គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្ររបស់ខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ប្រធាន |
| ២- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៤- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម **ទ្រាំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- ឯកឧត្តម **៦ល ម៉ាន់សាវ៉ាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៧- ឯកឧត្តម **ខី តាឃី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម **យុទ្ធ ភូថង** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៩- ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១០- ឯកឧត្តម **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- ឯកឧត្តម **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១២- ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៣- ឯកឧត្តម **ប៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការ គ.អ.ឆ.ក | សមាជិក |
| ១៤- ឯកឧត្តម **យន្ត មីន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៥- ឯកឧត្តម **ឆាយ ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦- ឯកឧត្តម **ឡោ ដាវុធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៧- ឯកឧត្តម **ម៉ាន់ មុនីនាថ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃ ក្រសួងបរិស្ថាន និងជាអគ្គលេខាធិការរង គ.អ.ឆ.ក | សមាជិក |
| ១៨- ឯកឧត្តម **ហាខ្យ សុគតសំភារ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាអគ្គលេខាធិការរង គ.អ.ឆ.ក | សមាជិក |
| ១៩- ឯកឧត្តម **សូ សុខ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាអគ្គលេខាធិការរង គ.អ.ឆ.ក | សមាជិក។ |

**មាត្រា២.-**

ក្រុមការងារពិសេសនេះ មានភារកិច្ចគាំទ្រដល់ការអនុវត្តផ្ទាល់របស់គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្ររបស់ខេត្តព្រះសីហនុ នៅចំណុចចំនួន៥ ដូចខាងក្រោម៖

**១-ករណីបឹងព្រៃកទប់ ស្ថិតនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ:**

-ត្រូវចុះសិក្សាកំណត់អត្តសញ្ញាណអ្នកកាន់កាប់ដីពីភាពមិនប្រក្រតី(ឬភាពអនាធិបតេយ្យ) និងកំណត់និយាមកាច្បាស់លាស់ ដើម្បីស្នើសុំដាក់បឹងព្រៃកទប់ជាតំបន់អភិរក្ស ដោយព្រះរាជក្រឹត្យ។

**២-ករណីឆ្នេរឯករាជ្យស្ថិតនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ**

-ត្រូវចុះសិក្សានិងកំណត់តំបន់ឆ្នេរឯករាជ្យ ដែលត្រូវអភិវឌ្ឍនិងតំបន់អភិរក្សសម្រាប់សាធារណជនលំហែនិងកម្សាន្ត ស្របតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន ដោយនៅចំពោះមុខតម្រូវឲ្យធ្វើការរុះរើរបាំងរបង និងរៀបចំកែសម្រួលឲ្យសាធារណជនអាចចូលទៅកម្សាន្តឆ្នេរខ្សាច់នៅតំបន់ឆ្នេរនេះបាន។

-ផ្អែកលើលទ្ធផលនៃការសិក្សាខាងលើ និងដោយស្ថានភាពបច្ចុប្បន្នមានរបាំងរារាំងមិនអាចឲ្យសាធារណជនទៅលំហែ និងកម្សាន្តតំបន់ឆ្នេរខ្សាច់បាន ទាក់ទងនឹងគម្រោងវិនិយោគនិងការកាន់កាប់ឯកជន ត្រូវពិនិត្យជម្រើស ០២គឺៈ ១-ត្រូវដកយកមកធ្វើជាទ្រព្យសម្បត្តិរដ្ឋវិញ ដោយរដ្ឋដោះស្រាយចេញសំណងជូនតាមគោលការណ៍ច្បាប់ជាធរមាន ដើម្បីរៀបចំតំបន់នេះជាឆ្នេរសម្រាប់សាធារណជន ឬ ២-ផ្តល់ការអនុញ្ញាតឲ្យម្ចាស់វិនិយោគបន្តអភិវឌ្ឍ និងប្រើប្រាស់ស្របតាមច្បាប់និងបទដ្ឋានគតិយុត្ត ពិសេសសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបើកចំហឲ្យសាធារណជនអាចចេញចូលប្រើប្រាស់ និងកម្សាន្តឆ្នេរខ្សាច់នៅតំបន់ឆ្នេរឯករាជ្យបានដោយគ្មានរបាំងនិងការរារាំង។

**៣-ករណីឆ្នេរអូរត្រេះ ស្ថិតនៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ**

-ត្រូវសិក្សាអំពីវិធានការរុះរើសំណង់អនាធិបតេយ្យនៅតាមដីចំណីឆ្នេរ និងចាប់ផ្តើមធ្វើការអប់រំ និងផ្សព្វផ្សាយព្រមទាំងកំណត់ពេលវេលា និងកិច្ចសន្យាច្បាស់លាស់ជាមួយនិងអាជីវករនិងអ្នកតាំងទីលំនៅនៅទីនោះឲ្យរុះរើចេញដើម្បីរៀបចំជាឆ្នេរគំរូសាធារណៈសម្រាប់បម្រើសេវាកម្មទេសចរណ៍ និងការលំហែនិងកម្សាន្តឲ្យសក្តិសមជាឆ្នេរគំរូ ព្រមទាំងសិក្សាកំណត់ឲ្យមានអ្នកអភិវឌ្ឍតំបន់ឆ្នេរអូរត្រេះ (Developer) ឬជាអ្នកគ្រប់គ្រង (Site Manager) ដើម្បីធានាការគ្រប់គ្រងឆ្នេរឲ្យមាននិរន្តរភាព។

**៤-ករណីឆ្នេរអូរឈើទាល** (ទល់មុខដីក្រុមហ៊ុន សុខា អូតែល អតីតអារីស្តុន) **ស្ថិតនៅសង្កាត់លេខ៤** ក្រុងព្រះសីហនុ

-ត្រូវសិក្សានិងរៀបចំវិថីអូរឈើទាល (ផ្លូវប្រឡងឆ្នេរចម្ងាយ៥០ម៉ែត្រពីឆ្នេរខ្សាច់) បន្តទៅទិសខាងជើងមានទំហំទទឹងសមស្រប ដោយកាត់តាមដីក្រុមហ៊ុនសុខាអូតែល (អតីតអារីស្តុន) ស្របតាមបណ្តោយឆ្នេរសមុទ្រ។

-ដីចំណីឆ្នេរត្រូវរៀបចំជាសួនច្បារ និងឆ្នេរខ្សាច់ដែលនៅពីមុខផ្លូវនេះ ត្រូវថែរក្សានិងការពារសម្រាប់សាធារណជនលំហែនិងកម្សាន្ត ដោយមិនអនុញ្ញាតឲ្យសាងសង់សំណង់គ្រប់ប្រភេទ និងដោយផ្តល់សិទ្ធិឲ្យក្រុមហ៊ុន សុខា អូតែល ចូលរួមការពារនិងថែរក្សា

-សហការជាមួយក្រុមហ៊ុនសុខា អូតែល លើការរៀបចំនិងការសាងសង់ផ្លូវនិងសួនច្បារលើទីតាំងដីចំណីឆ្នេរនេះ

-គាំទ្រដល់គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ លើការរៀបចំនិងការសាងសង់ផ្លូវនិងសួនច្បារលើទីតាំងដីចំណីឆ្នេរនេះដែលក្រុមហ៊ុនសុខា អូតែល ជាអ្នកធានាទទួលបន្ទុកចំណាយលើការងារនេះ។

**៥-ករណីផ្ទៀលដីស្បែកខ្លាជូនប្រជាពលរដ្ឋ និងការដោះស្រាយបញ្ហាសំណង់លើទឹក លើដីចំណីឆ្នេរ និងឆ្នេរខ្សាច់នៅកោះរ៉ុង ស្ថិតនៅសង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ**

-ត្រូវសិក្សារកដំណោះស្រាយប្តូរទីតាំងសំណង់ទាំងឡាយដែលបានបោះទីតាំងនៅលើទឹក លើដីចំណីឆ្នេរ និងឆ្នេរខ្សាច់នៅកោះរ៉ុង ឲ្យទៅនៅលើដីផ្អែកខាងក្នុងនៃកោះរ៉ុង

-ត្រូវសិក្សាដើម្បីស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលកាត់ដីរដ្ឋដែលនៅសល់ពីគម្រោងវិនិយោគផ្អែកខាងក្នុងនៃកោះរ៉ុងសម្រាប់ជាថ្នូរផ្តល់ជូនអ្នកដែលត្រូវឲ្យប្តូរទីតាំងនេះវិញ

-ត្រូវចងក្រងគំរូបទពិសោធនៃការប្តូរទីតាំងនេះ សម្រាប់អនុវត្តការដោះស្រាយសំណង់លើទឹក លើដីចំណីឆ្នេរ និងឆ្នេរសមុទ្រនៅតំបន់ផ្សេងទៀត ក្នុងតំបន់ឆ្នេរសមុទ្រទាំងមូលនៃខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និង ខេត្តកែប។

ក្រុមការងារពិសេសនេះ ធ្វើរបាយការណ៍ជាប្រចាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន ជូនគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ធ្វើការបូកសរុបនិងរាយការណ៍ជូនរាជរដ្ឋាភិបាល។

ក្រុមការងារពិសេសនេះ ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៣.‑**

គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ មានភារកិច្ចអនុវត្តផ្ទាល់លើចំណុចទាំង៥ ដូចមានចែងក្នុងមាត្រា២។

**មាត្រា៤.‑**

គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ មានកញ្ចប់ថវិកាពិសេសសម្រាប់អនុវត្តផ្ទាល់លើចំណុចទាំង៥ ដូចមានចែងក្នុងមាត្រា២។

**មាត្រា៥.‑**

ក្រុមការងារពិសេសនេះ អាចបង្កើតក្រុមការងារជំនួយការបច្ចេកទេស ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

**មាត្រា៦.‑**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧.‑**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន អាជ្ញាធរខេត្តដែលពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -សាលាខេត្តព្រះសីហនុ
- -ដូចមាត្រា៧
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ